# ២៣- រឿងអ្នកតាយាយងួន

របស់លោក ជឹម ឈុំ សង្កាត់ឫស្សីព្រៃ ស្រុកសណ្តាន់ ខេត្រកំពង់ធំ

ប្រជុំរឿងព្រេងខ្មែរភាគ ៨ ពីទំព័រទី ១៥៥ – ១៧៥

---

## អំពីអ្នកតា លោកយាយ ឬយាយងួន

អ្នកតានេះ ស្ថិតនៅក្នុងសង្កាត់ទំរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។ អ្នកស្រុកជាចំណុះអ្នកតាមាន ៩ ភូមិ1 គឺភូមិសែន រនាម សំរោង ក្បាលដំរី និងទំរីង ក្នុងសង្កាត់ទំរីង ហើយនឹងភូមិខោស អន្ទះ ទំអរ និងឫស្សីព្រៃ ក្នុងសង្កាត់ឫស្សី ស្រុកសណ្តាន់ ។ ភូមិទាំង ៩នេះជាភូមិនៅរាយគ្នាក្នុងព្រៃធំ លើទួលខ្ពស់ជាងដីធម្មតា សណ្ឋានជាភ្នំ មានវត្តតែមួយ ហៅថាវត្តក្បាលដំរី ក្នុងសង្កាត់ទំរីង ។ ចម្ងាយជាបន្តបន្ទាប់គ្នា ពីភូមិមួយទៅភូមិមួយ ប្រមាណជាពី ១ ទៅ ៤ គ.ម. ។ ក្នុងរង្វង់ភូមិទាំង ៩ ក្នុងសង្កាត់ទាំងពីរ ដូចខាងលើនេះ ពីបរមបុរាណមក គេនិយមហៅថា តំបន់ក្បាលដំរី ពីព្រោះមានតែវត្តក្បាលដំរីមួយនេះជាទីសិក្សានិងជាទីប្រជុំធ្វើបុណ្យទាន ។

ខ្ទមអ្នកតា តាំងនៅក្បែររទេះ ដែលឡើងពីភូមិតាមជួរមាត់ស្ទឹងសែនទៅកាន់សង្កាត់ទំរីង និងសង្កាត់ឫស្សីព្រៃ តំបន់ក្បាលដំរី ចម្ងាយពីទីប្រជុំស្រុកទៅ ប្រមាណជា ៤២ គ.ម. ។ អ្នកតានោះគ្មានរូបចម្លាក់ជាតំណាងទេ មានតែដីដុះខ្ពស់ឡើង នៅក្រោមដំបូលខ្ទមសណ្ឋានជាដំបូកប៉ុណ្ណោះ ។

បើគេចង់ធ្វើដំណើរពីសាលាស្រុកសណ្តាន់ ទៅកាន់ទីអ្នកតា គេត្រូវទៅតាមផ្លូវដែលកាន់សង្កាត់ទំរីង និងសង្កាត់ឫស្សីព្រៃ គឺគេត្រូវធ្វើដំណើរតាមផ្លូវរទេះ ឆ្ពោះមុខទៅទិសអាគ្នេយ៍ ។ ក្រោយពីបានឆ្លងកាត់វាលស្រែ ដ៏ធំធេងមួយរួចហើយ គេនឹងបានដល់ភូមិនិងវត្តមួយហៅថាភូមិនិងវត្តអណ្តូងព្រីង ក្នុងសង្កាត់ឈើទាល (សណ្តាន់) ។ តពីនេះទៅទៀត ផ្លូវរទេះនឹងបំបែរដំណើរគេឲ្យឆ្ពោះមុខត្រង់ទៅទិសខាងកើតរហូត ។ លុះឆ្លងកាត់ព្រៃធំនិងព្រៃរបោះដ៏ស្ងាត់ជ្រងំពីរលើកមក ដែលជួនកាលមានពើបប្រទះនឹងពួកម្រឹគទាំងឡាយ ដែលវាដើររកស៊ីក្បែរផ្លូវនាព្រៃទាំងនេះ នាំឲ្យគេភ្ញាក់ភ័យ នឹងមានការកម្សាន្តភ្នែកខ្លះ ដោយមិនដែលបានឃើញ នឹងបានឆ្លងអូរពីរដ៏មានទឹកថ្លាឆ្វង់ មើលឃើញដីនិងត្រីហែលច្រវាត់ ដែលហូរបណ្តោយតាមមាត់ព្រៃ ហាក់ដូចជាខ្សែខណ្ឌព្រំដែនព្រៃធំ និងព្រៃរបោះនោះ ឲ្យមានភាពដាច់ដោយឡែកពីគ្នាទាំងមានព្រឹក្សាម្លប់ត្រឈឹងត្រឈៃ ដុះក្បែរច្រាំងប្របផ្លូវ ជាទីសម្រាកនៃអ្នកដំណើរទាំងឡាយ មុននឹងបន្តដំណើរទៅមុខទៀត ។ មកដល់ទីនេះ ទេសភាពបានប្រាប់គេឲ្យដឹងថា ចូលដល់សង្កាត់ទំរីងហើយ ។ លុះឆ្លងព្រៃរបោះផុតទៅ គេត្រូវឡើងទួលចូលដល់ព្រៃស្រោង "ស្រឡៅដុះរាយលាយសុក្រំ" គេនឹងឃើញនៅតាមបណ្តោយមាត់ផ្លូវខាងជើង (ខាងឆ្វេង) នូវថ្លាមួយបួនជ្រុងទ្រវែង ទំហំប្រមាណជា ៥០ ម X ២០ ម ។ នៅទន្ទឹមនឹងចុងខាងកើតនៃទីថ្លានេះ ក្បែរមាត់ផ្លូវខាងត្បូង (ខាងស្តាំ) គេនឹងឃើញខ្ទមមួយសណ្ឋានជាផ្ទះ

តៀម សសរខ្លឹម ប្រក់ក្បឿងជញ្ជាំងក្តារ ។ នៅក្នុងនោះមានដំបូកមួយដ៏មានគ្រឿងសក្ការបូជាផ្សេងៗ មានទៀនធូប ទង់ ពិតាន ជាដើម ដោតនិងព្យួរច្រូងច្រាងរយោនរយាន នេះហើយជាខ្ទមអ្នកតា យាយងួន ដែលអ្នកស្រុកនិងអ្នកដំណើរទាំងឡាយតែងគោរពបូជា ។ បើធ្វើដំណើរពីនេះទៅមុខទៀត ប្រមាណជា ១ គ.ម. គេនឹងបានដល់ភូមិមួយ ហៅថាភូមិសែន ជាភូមិបង្កើយដែលអ្នកភូមិអាចថែរក្សាអ្នកតានេះផ្ទាល់ដៃ បានជិតដល់ជាងគេ ។ តពីទៅទៀត ប្រមាណជាង ១ គ.ម គេនឹងដល់ភូមិនិងវត្តក្បាលដំរី ក្នុងសង្កាត់ទំរឹង ។ បើចេះតែបន្តដំណើរទៅមុខទៀត (ត្រង់ទៅកើត) ប្រមាណជា ៩ គ.ម គេនឹងដល់ភូមិមួយទៀត ដែលមានអក្ខរាសរសេរនៅលើបន្ទះក្តារ បោះក្បែរច្រកចូលថា "ភូមិខោស សង្កាត់ឫស្សីព្រៃ" ។ គេរអែងយាយងួនពន់ពេក2 ដោយគេជឿចាក់ថា យាយងួន មានឥទ្ធិពលអស្ចារ្យណាស់ អាចជួយសម្រេចបានយ៉ាងស័ក្តិសិទ្ធិ តាមសំណូមពរ (ការបន់សព្វបែបយ៉ាង) របស់ជនណាដែលគោរពរាប់អានគាត់ដោយស្មោះស្ម័គ្រ ហើយផ្តន្ទាទោសយ៉ាងទាន់ហន់ ជនណាដែលទៅដល់ហើយ ព្រហើន បែបចង់មើលងាយ ដោយឫក្សរឹងត្អឹង មិនព្រមចំណុះ មិនគោរពគាត់ ។ ពិធីឡើងអ្នកតានេះ ក្នុង១ឆ្នាំមានធ្វើពីរដង នៅខ្មើតខែពិសាខម្តងខ្មើតខែមាឃម្តង ប៉ុន្តែគេមិនហៅថាឡើងអ្នកតាទេ គេហៅថាធ្វើបុណ្យរាប់បាត្រដារលោកយាយ ពីព្រោះមិនមែនជារៀបចំពិធីឡើង ដោយមានគ្រឿងសំណែន ដូចអ្នកតាឯទៀតៗទេ គឺគេធ្វើបុណ្យតាមរបៀបព្រះពុទ្ធសាសនាយើងសុទ្ធៗតែម្តង គឺមានរៀបចំរាជវ័តិ ពូនភ្នំខ្សាច់ ពេលល្ងាច និមន្តព្រះសង្ឃចម្រើនព្រះបរិត្ត ព្រឹកឡើងរាប់បាត្រដារបញ្ចូនរួចហើយ ប្រគេនចង្ហាន់ព្រះសង្ឃឆាន់ ពេលព្រឹកនិងថ្ងៃត្រង់ ។ ដល់ពេលរសៀល និមន្តព្រះធម្មកថិកសម្តែងធម៌ទេសនា ដោយសាស្រ្តាចម្លងបុណ្យ លុះចប់ហើយប្រគេនទេយ្យវត្ថុដល់ព្រះសង្ឃនិងអាចារ្យ ក៏សន្មតថាចប់កិច្ចនេះត្រឹមតែប៉ុណ្ណោះ ។

ការធ្វើបុណ្យនេះ ធ្វើមួយយប់មួយថ្ងៃក៏មាន ពីរយប់ពីរថ្ងៃក៏មាន បីយប់បីថ្ងៃក៏មាន តាមការជំនុំព្រមព្រៀងគ្នា ។ ការកំណត់ធ្វើ គឺក្នុងមួយឆ្នាំពីរលើកជាដាច់ខាត នៅខ្មើតខែពិសាខ ដើមឆ្នាំម្តង ខ្មើតខែមាឃម្តង ដូចបានពោលមកហើយ ប៉ុន្តែធម្មតាច្រើនតែអាចារ្យជាអ្នកផ្តើមជំនុំ នឹងកំណត់ពេលវេលាដែលត្រូវធ្វើ ពីព្រោះអ្នកតានេះគេទុកជាអាទិទេពពំនឹងនៃអ្នកស្រុក។

ក្រោយដែលបានកំណត់ពេលវេលា ដែលត្រូវធ្វើរួចហើយ មុននេះពីរឬបីថ្ងៃ គេនាំគ្នាពីគ្រប់ភូមិ ទៅរៀបចំទីកន្លែងអ្នកតា មានសម្អាតទីធ្លា សង់រោងសម្រាប់ព្រះសង្ឃ ធ្វើរាជវ័តិ ពូនភ្នំខ្សាច់ជាដើម ។ បើបុណ្យនេះត្រូវធ្វើច្រើនថ្ងៃ គេត្រូវរៀបចំទីកន្លែង សម្រាប់ឲ្យអ្នករៀបចំបុណ្យស្នាក់អាស្រ័យ ដូចជាជើងក្រានទឹក ឧស ជាដើម ប៉ុន្តែគេនិយមធ្វើច្រើនថ្ងៃតែក្នុងខែមាឃ ព្រោះជារដូវគ្មានភ្លៀងធ្លាក់ ។ ក្នុងឱកាសបុណ្យនោះ នៅវេលាយប់ ក្រោយពេលដែលព្រះសង្ឃចម្រើនព្រះបរិត្តរួច មានលេងល្បែងផ្សេងៗទៅតាមកាលសម័យ ដើម្បីកំដរបរិយាកាសផង ។ ជំនាន់បុរាណ មានលេងលោតអន្ទាក់ ឈូង រុញអង្រែ ទាញព្រ័ត និងច្រៀងតគ្នាប្រុសស្រី បទកញ្ចាញ់ចេក បទកញ្ញាឈូង ចោលឈូង ប្របកែ... ។ល។ ចាស់ៗលេងភ្លេងខ្មែរបុរាណ សម័យបច្ចុប្បន្ន ច្រើនលេងយីកេនិងរាំវង់ ។ នៅខែពិសាខ គេកម្រធ្វើច្រើនថ្ងៃណាស់ ព្រោះពិបាកដោយមានភ្លៀងច្រើន ធ្វើតែមួយថ្ងៃមួយយប់ ហើយគេមិនសូវទាំងទៅដេកនៅឯទីកន្លែងអ្នកតានោះផង ។ ទាំងព្រះសង្ឃទាំងគ្រហស្ថ គេគ្រាន់តែទៅជួបជុំគ្នាចម្រើនព្រះបរិត្ត រួចហើយក៏ត្រឡប់មកឯវត្តទៅផ្ទះវិញ ដល់ព្រឹកឡើងចម្អិនអាហារពីផ្ទះរួចស្រេច ទើបនាំគ្នាទៅម្តងទៀត ។ រៀបបាត្រដារបញ្ចូននិងឆាន់ ពេលព្រឹកនិង

ថ្ងៃត្រង់រួចហើយ ជូនកាលមានទេសនាឆ្លង ជូនកាលក៏គ្មានទេ សន្មតថាហើយស្រេច នាំគ្នាត្រឡប់មកផ្ទះវិញរៀងខ្លួន ។

ក្រោយពេលដែលរាប់បាត្រ និងព្រះសង្ឃសូត្រធម៌ចប់មួយលើកហើយ មុននឹងរៀបចង្ហាន់ប្រគេនព្រះសង្ឃឆាន់ គេរៀបពិធីបញ្ជូនគេរំលែកភោជនាហារចេញពីកន្ទោងដារ ។ អ្នកតាចូលមកអង្គុរមកគ្រវាស បោយយកពីខ្លួនប្រាណនៃអ្នកដែលមកជួបជុំទាំងប៉ុន្មាន មេជំងឺតម្កាត់ឧបទ្រពចង្រៃ បញ្ចេរជះទៅក្នុងសង្សឹកជាច្រើនលើកច្រើនសារ ហើយក្នុងពេលជាមួយគ្នានោះ អ្នកអង្គុយជិតសង្សឹកពីរ -បីនាក់ក៏តាំងច្រូចទឹកសែនដង្ហោយហៅពួកខ្មោច ព្រាយ បិសាច រាជភូតជាមេជំងឺ ធ្វើឲ្យគេឯងឈឺថ្កាត់ទាំងប៉ុន្មាន នៅក្នុងស្រុកភូមិជាចំណុះអ្នកតានេះ ឲ្យចូលមកសេពសោយគ្រឿងក្រយាបូជា ដែលគេរៀបចំឲ្យនៅឯសង្សឹក ។ លុះសែនហៅគ្រប់ ៣ដងហើយ ព្រះសង្ឃសូត្រអាកាដ្ឋា ទើបគេបញ្ជាឲ្យសែងសង្សឹកចេញទៅហើយ ក៏ដើរតាមបាចអង្គុរពីក្រោយបណ្ដើរដេរាបទៅ ដល់ទីកន្លែងដែលត្រូវដាក់សង្សឹកចោល ទើបត្រឡប់មកវិញទាំងអស់គ្នា ហើយសម្ទឹងប្រាប់គេរាល់គ្នាថា "យើងបញ្ជូនពួកវាឲ្យទៅអស់ហើយ" ។ ឯពួកអ្នកស្រុកជាពិសេសពួកអ្នកដែលមកជួបជុំក្នុងពេលបុណ្យ ក៏មានទឹកមុខរីករាយញញឹមញញែម ដែលអាចឲ្យសម្គាល់បានថា ៖ មានជំនឿជាក់ថាមុខជានឹងបានសេចក្ដីសុខសប្បាយពិតប្រាកដមែន ព្រោះអ្នកតាបានបញ្ជូនមេឧបទ្រពចង្រៃទៅអស់ហើយ ។ ពិធីបញ្ជូននេះគេនិយមធ្វើតែនៅថ្ងៃបង្ហើយបុណ្យ ។

អំពីតង្វាយៈ វត្ថុដែលត្រូវថ្វាយគ្មានកំណត់ទេ តាមតែអ្នកបន់ថ្វាយអ្វី ក៏ថ្វាយហ្នឹងទៅ បំណាន់ត្រូវយកទៅថ្វាយដល់ទីកន្លែង ប៉ុន្តែគេមិនដែលបន់ដាក់គ្រឿងស្រវឹងទេ ដោយគេដឹងថា អ្នកនេះជាអ្នកតាសច្ចំមានសីលធម៌ មិនមែនជាពួកព្រាយបិសាចទេ ។

បើគេមានការបារម្ភចំពោះហេតុណាមួយ ហើយចង់ឲ្យបានសុខក្សេមក្សាន្ត ដូចជាឲ្យជួយការពារជំងឺតម្កាត់ផ្សេងៗ មានអាសន្នរោគជាដើម កុំឲ្យកើតមានដល់ស្រុកភូមិ ឬ ក៏សុំឲ្យបានសុខសប្បាយ នៅពេលមានកិច្ចការក្នុងវត្ត ដូចជារៀបស្ថាបនាកុដិ សាលា ព្រះវិហារ ឬ ធ្វើបុណ្យទានធំជាដើម គេត្រូវរៀបរណ្ដាប់បញ្ចាន់រួបគឺៈ សំណែនមានបង្អែម ចម្អាប ស្លាធម៌ ១គូ ជម ៤ សំពត់ស ៥ហត្ថ ប្រាក់មួយរៀល អង្ករ ទៀន ធូប ស្លា បារីប្រេងម្សៅ និងទឹកបាន3 មួយស្ពក ហើយប្រគំភ្លេងមានស្គរជី និងប៉ីអរ ។ កាលបើបានរៀបដូច្នេះហើយ អ្នកតាក៏ចូលមក រាំលេងតាមភ្លេងអស់មួយបទយ៉ាងវែងទើបឈប់ រួចហើយផឹកទឹកបាន ស៊ីស្លា ឬ ជក់បារីនិងលាបប្រេងម្សៅហើយអង្គុយសម្រាក ចាស់អារក្សទាក់ទងសួរ សុំឲ្យបានសុខសប្បាយទៅតាមការ ឯអ្នកតាតែងតែទទួលព្រមជានិច្ច ប៉ុន្តែច្រើនប្រាប់អ្នកស្រុកឲ្យត្រណម4 ផង ។

ក្នុងពេលនោះ បើអ្នកណាមានការសាទុក្ខដូចម្ដេច ឬចង់ដឹងហេតុអ្វីមួយចំពោះតែខ្លួនម្នាក់ៗ អាចសួរបានតាមត្រូវការ ដូចជារករបស់បាត់ ឬទស្សន៍ទាយមើលមនុស្សឈឺជាដើម រួចហើយ បើអស់នរណាសន្ទនាអ្វីតទៅទៀត ទើបអ្នកតាចេញទៅវិញ ។

ឯការរៀបបញ្ចាន់បែបនេះមានកំណត់កាលទេ ចង់រៀបនៅពេលណាក៏បាន ឲ្យតែមានការគួររៀប ប៉ុន្តែគេនិយមរៀបតែក្នុងទីវត្ត ពីព្រោះការទាក់ទងនឹងអ្នកតានេះ ច្រើនមានទាក់ទងតែក្នុងការជាសាធារណ ឯចំពោះឯកជនវិញគ្មានទម្លាប់ធ្វើដូចនេះទេ ។ បើនរណាមានការត្រូវបន់ត្រូវថ្វាយអ្វី ត្រូវទៅបន់ថ្វាយដល់កន្លែងខ្ទមឯណោះ ។ នៅពេលធ្វើបុណ្យប្រចាំក្នុងមួយឆ្នាំពីរដងនោះ គេគ្មានរៀបរណ្ដាប់អ្វីដូចជានៅពេល

បញ្ជាន់ទេគ្រាន់តែយកទៀនធូបទៅអុជថ្វាយ ប្រាប់ប្រងនៅខ្ទមជាការស្រេច ប៉ុន្តែរូបអ្នកនិងគោកជាដើមត្រូវដាក់ជាមួយដែរ ដើម្បីទុកសម្រាប់ត្រូវការនៅពេលបញ្ជូនសង្ឃឹកដូចបានពោលមកហើយ ។ នៅពេលឥតរូប 5ម្តងៗ អ្នកតាច្រើនចូលរូបថ្មីទៀតនៅពេលដែលរៀបបញ្ជូនក្នុងឱកាសធ្វើបុណ្យប្រចាំឆ្នាំនេះឯង ឬ នៅពេលដែលគេរៀបបញ្ជាន់ដោយមានការជាចាំបាច់ម្តងៗ ដូចបានពោលមកហើយនោះដែរ ។

# ប្រវត្តិអ្នកតា

តាមសេចក្តីដំណាលតៗមកថា ត្រង់នាទីដីសង្កាត់ទំរីងនិងសង្កាត់ឫស្សីព្រៃ (ស្រុកសណ្តាន់) សព្វថ្ងៃ ដែលបរមបុរាណនិយមហៅថា តំបន់ក្បាលដំរីនោះ ពីអតីតកាលមក ជាព្រៃរហោឋានគ្មានមនុស្សនៅទេ មានតែពួកពាឡម្រឹគអាស្រ័យនៅជាស្រុកភូមិរបស់វា ។ លុះក្រោយមកមានពួកឧទ្ទាមចូលទៅនៅ តាមការណែនាំដោយសមព្រមត់នៃព្រានព្រៃ ម្នាក់ ហៅថា "ព្រានហ្លួង6" ដែលគាត់ធ្លាប់មកបរបាញ់ក្នុងព្រៃនេះ ស្គាល់កន្លែងសព្វគ្រប់គឺ គាត់ចំណាំបានថា ត្រង់នេះមានជាំត្រង់នោះមានអូរ ទួលទំនាប ។ល។ ហើយគាត់បានទាំងសន្មតនាមនៃត្រង់ទាំងនោះៗ សឹងមានឈ្មោះហៅជាប់មកដល់សព្វថ្ងៃ7 ។

ពួកឧទ្ទាមដែលចូលមកនេះ គឺនៅជ្រកលាក់ខ្លួនដោយកន្លែងផ្សេងៗពីគ្នា ដើម្បីកុំឲ្យមានដំណឹង រកស៊ីកាប់ចម្ការតូចតាច ដាំស្រូវ ពោត នឹងបន្លែបន្តិចបន្តួច ផ្សំជាមួយដំឡូង ក្តួចនិងរកផលក្នុងព្រៃខ្លះដូចជាបណ្តាញសត្វ យកឃ្មុំ និងបេះផ្លែឈើជាដើម ហើយកាន់ទំនៀមទម្លាប់តាមភាពជាអ្នកនៅព្រៃភ្នំ តាមព្រានព្រៃនោះទាំងអស់ ក្រោយមក មានអ្នកសំណាក់មកពីនេះខ្លះពីនោះខ្លះ ទៅនៅផ្សំផងទៀត ក៏កាន់តែកើនចំនួនក្រាស់ក្រៃលក្នុងកន្លែងនីមួយៗ ក៏រីកសាយកើតជាភូមិធំៗ បន្តិចឡើង ប៉ុន្តែពុំទាន់មានវត្តអារាម និងពុំទាន់មានក្រសួងរាជការត្រួតត្រាជិតដល់នៅឡើយទេ ។ ជំនាន់នោះគ្មានការធ្វើបុណ្យទានអ្វីផ្នែកខាងព្រះពុទ្ធសាសនាធំដុំទេ ច្រើនទីពឹងលើអ្នកតានិងព្រាយបិសាចតែប៉ុណ្ណោះ ព្រោះក្នុងគ្រានោះ អ្នកដែលចូលទៅនៅទាំងប៉ុន្មាន សុទ្ធតែចូលទៅនៅដោយលួចលាក់ ។ បណ្តាមនុស្សទាំងឡាយ ដែលរស់នៅនាតំបន់ដូចខាងលើ មាននាងសាវកែម្នាក់ឈ្មោះ ងួន នៅភូមិព្រាហ្មណ៍ ជាមនុស្សកំព្រា នៅរកស៊ីតែម្នាក់ មានផ្ទះតូចមួយខ្ទង សង់ដាច់ឆ្ងាយពីគេ ក្បែរផ្លូវធ្លាចុងភូមិខាងកើត ។

នៅពេលអធ្រាត្រនៃរាត្រីមួយ អ្នកស្រុក ជាពិសេសអ្នកដែលនៅជិតផ្លូវធ្លា ដែលកំពុងនិទ្រាលក់យ៉ាងស្កប់ស្កល់ ស្រាប់តែភ្ញាក់ក្រញាងដោយឮសូរសន្ធឹកមនុស្សជិះសេះ និងដើរយ៉ាងច្រើនតាមធ្លាពីចុងភូមិខាងលិចទៅកើត ហាក់ដូចជាសន្ធឹកគេដង្ហែបុណ្យអ្វីមួយ ហើយបាត់សូរត្រង់មុខនាង ងួន ។ ក្រោយដែលបានឮសូរសន្ធឹកមក គេបានក្រោកអើតមើលតាមទៅ ឃើញមានរស្មីច្រាលរន្ទាលពេញតែផ្ទះនាង ងួន ប្រហែលមួយចម្អិនបាយ ក៏បាត់ពន្លឺនោះស្ងួនឈឹងទៅវិញ ។ លុះព្រឹកឡើង ពួកអ្នកស្រុកនាំគ្នាពិនិត្យមើលដានតាមផ្លូវ ពុំមានឃើញមានស្នាមដានអ្វីបន្តិចបន្តួចសោះ មិនអស់ចិត្តក៏នាំគ្នាទៅសួរដល់នាង ងួន ទៀត នាង ងួន ឆ្លើយថា នាងគ្មានបានដឹងអ្វីទាំងអស់ ។ ពួកអ្នកស្រុកមានការងឿងឆ្ងល់ពន់ពេក ចំពោះរឿងដ៏ចម្លែកនេះ ប៉ុន្តែបន្ទាប់មក បានឃើញនាងចាប់ទម្ងន់ដោយគ្មានប្តី ទើបគេយល់ថានាងមានគភ៌ ដោយមានហេតុភេទដ៏ចម្លែកពីពេលមុននោះឯង ទើបគេជំនុំគ្នាដោយស្មាត់ថា : ប្រហែលជាមានអ្នកមានបុណ្យបារមីមកចាប់ផ្ទៃនាងហើយមើលទៅ យើងត្រូវចាំមើលជួយថែទាំនាងផង ក្រែងលោពិតមែន យើងនឹងបានពឹងបារមីនោះ ។ តាំងពីពេលនោះមក នាងងួនត្រូវបានអ្នកស្រុកជួយឧបត្ថម្ភគ្រប់បែបយ៉ាងទាំងអស់ ។ លុះដល់គ្រប់ខែដប់

នាង ង្ងួន ក៏សម្រាលបុត្រនោះមក ឃើញថាមានបុណ្យបារមីដ៏អស្ចារ្យពិតមែន គឺភេទប្រុស សម្រាលចាកឧទរមក ចេះដើរ ចេះនិយាយភ្លាមហើយមាត់ទិព្វផង ។ បុត្រនាង ង្ងួនបានប្រកាសប្រាប់គេឯងរាល់គ្នាថា "ខ្ញុំឈ្មោះទុមបារមី ព្រះឥន្ទ្រលោកប្រើមក" ហើយប្រាប់នាង ង្ងួនជាម្ដាយទៀតថា "កូននៅទីនេះជាមួយនឹងបានតែប្រាំពីរថ្ងៃទេ កូននឹងលាម៉ែទៀតទៀតហើយ កូនដាំកូនពោធិមួយដើមទុកជូនម៉ែជាទីរឭក បើម៉ែមានទុក្ខធុរៈដូចម្ដេច គ្រាន់តែនឹកដល់ខ្ញុំជាកូន ខ្ញុំនឹងមកជួយម៉ែឲ្យបានសម្រេចដូចប្រាថ្នាទាន់ចិត្ត មួយទៀត ដែលថាខ្ញុំនឹងលាម៉ែទៅទៀតនោះ សន្យាត្រឹមតែមែកពោធិដែលខ្ញុំដាំនេះធំបែកមែកដាបដល់ដី ខ្ញុំនឹងត្រឡប់មកជួបនឹងម៉ែវិញហើយ" ។ លុះដល់គម្រប់ប្រាំពីថ្ងៃ កុមារទុមបារមី ក៏បន្ទន់កាយដោយប្រណីតប្រណម្យលានាង ង្ងួន ចេញបាត់ទៅ ។

ចាប់តាំងពីពេលនោះមក នាង ង្ងួន ក៏ក្លាយខ្លួនទៅជាវត្ថុស័ក្ដិសិទ្ធិមួយ ដោយមានមាត់ទិព្វ អាចញ៉ាំងសេចក្ដីប្រាថ្នារបស់មនុស្សទាំងឡាយ ឲ្យសម្រេចបានដូចចិត្តភ្លាមៗ ដោយគ្រាន់តែនឹកដល់គុណទុមបារមី ជាកូនរបស់នាង ឲ្យមកជួយតែប៉ុណ្ណោះ ។ ដោយឃើញនាងមានឥទ្ធិឫទ្ធិដូច្នេះ មនុស្សទាំងឡាយបានលើកនាងជាទីគោរពសក្ការ និងជាទីពឹងទីរឭកស្មើជីវិតរៀងៗខ្លួន បាននាំគ្នាហៅថានាង ង្ងួន ថា "លោកយាយៗ" ឬលោកយាយ ង្ងួន កាលណាកំបាំងមុខគាត់ ។

បន្ទាប់មកមានដំណាលថា មានសៀមបានចូលមកលុកលុយប្រទេសខ្មែរយើង បានលើកទ័ពចូលមករាតត្បាតកៀរយកខ្មែរធ្វើជាឈ្លើយ ដែលហៅ "សៀមកៀរ" ។ តាមសេចក្ដីដំណាលថា សៀមនោះពូកែណាស់មានព្រាយខ្សឹប អ្នកណាទៅពួនកន្លែងណា ក៏មិនកំបាំងដែរវាតាមទៅរកឃើញទាំងអស់ វាចាប់ដោតស្លឹកត្រចៀកផង ។ ម្ល៉ោះហើយពួកបណ្ដាជនដែលនៅក្នុងតំបន់ផ្សេងៗ ដោយបានឮល្បីថា យាយ ង្ងួន មានឫទ្ធិពូកែខ្លាំងណាស់ ក៏នាំគ្នារត់ចូលមកជ្រកនៅក្នុងតំបន់យាយ ង្ងួន នេះជាច្រើន ។ ថ្ងៃមួយ ពួកទ័ពសៀមលើកគ្នាមកៗជួបនឹងយាយ ង្ងួន កំពុងដាំបាយនឹងកូនឆ្នាំងតូចមួយ នៅផ្ទះគាត់ដែលនៅដើមផ្លូវ ពួកទ័ពសៀមបានកំហែងប្រុងនឹងចាប់ចងគាត់ បណ្ដើរឲ្យទៅតាមរកមនុស្សដែលគាត់លាក់ តែយាយ ង្ងួន បាននឹកដើមដល់កូនឲ្យមកជួយ ហើយគាត់ឃាត់ពួកទ័ពនោះថា "លោកចៅអើយកុំធ្វើបាបយាយ ចាំពិសាបាយឲ្យឆ្អែតទាំងអស់គ្នាសិន សឹមយាយជូនទៅ នេះនែបាយ! យាយដាំជិតឆ្អិនហើយ" ។ មេទ័ពក្រេវក្រោធកំហាកកំហែងស្ដីឲ្យថា "នែ ! យាយឯងកុំនិយាយលេងជាល្បែង បែបចង់មើលងាយ បាយយាយឯងមួយកូនឆ្នាំងអួតចង់ឲ្យគេស៊ីឆ្អែតអស់មួយកងទ័ព ប្រយ័ត្នណា ! យាយឯងមិនស្គាល់យើងទេ?” “ចាសលោក ! យាយចាស់ហើយ មិនចេះនិយាយលេងទេ បើលោកចង់ជ្រាប លមើលសិនទៅ បើលោកពីសាមិនឆ្អែត ខ្ញុំសុខចិត្តប្រគល់ជីវិតជូន បើពីសាមិនអស់ ត្រូវលោកថយទៅនគរលោកវិញភ្លាម" ។ ទទួលក្នុងពេលនោះ ជាពេលដែលកងទ័ពត្រូវបង្អង់ រៀបចំបាយបរិភោគពេលព្រឹកផង មេទ័ពក៏នៅស្ងៀម ប៉ុន្តែគ្មានស្ដាប់ពាក្យយាយ ង្ងួន នេះបន្តិចបន្តួចសោះទេ គេគិតស្រេច ចាំតែពួកកងទ័ពបរិភោគរួច ចាប់យាយ ង្ងួន បណ្ដើរទៅតែម្ដង ។ ឯយាយ ង្ងួន កាលបើបានដាំស្លឆ្អិនហើយ ក៏ដោះដួសមួយកូនស្លក លើកទៅជូនមេទ័ព ។ ដោយខឹងខ្លាំងពេកមេទ័ពមិនទទួល ចង្អុលឲ្យយកទៅកូនទាហានម្នាក់ ។ ឯកូនទាហាននោះក៏ទទួលយកទៅបរិភោគ ។ លុះបរិភោគទៅវាឆ្ងាញ់ខ្លាំងណាស់គិតថា ម្ហូបមួយកូនស្លកនេះ បង្ហើយឲ្យអស់តែម្នាក់ឯង មិនប្រាប់ដល់អ្នកណាទេ ប៉ុន្តែបរិភោគមិនអស់សោះ ពោះតែតឹង មាត់តែ ឆ្ងាញ់ អាហារនៅតែដដែលគ្មានរំលោះ ដរាបដល់ណែនពោះក្រោកមិនរួច ក៏ដឹងតៗគ្នាពីម្នាក់ទៅម្នាក់ នាំគ្នាចូលមកបរិភោគតៗគ្នា ឆ្អែតស្ទើរដើរមិនរួចរាល់គ្នា អស់

ទាហានមួយកងទ័ព មិនអស់អាហារមួយកូនស្ពករបស់យាយ ងួន នោះទាល់តែសោះ ។ ដោយឃើញហេតុអស្ចារ្យមេទ័ពសៀមគិតឃើញថា "យាយនេះមានឫទ្ធិពូកែខ្លាំងណាស់ គ្រាន់តែបាយគាត់មួយស្ពក ទាហានមួយកងទ័ពស៊ីមិនអស់ទៅហើយ ចំណង់បើតតាំងនឹងគាត់តទៅទៀត ដឹងជាទទួលគ្រោះថ្នាក់ដល់ប៉ុណ្ណាទៅ? ។ រួចហើយមេទ័ព ក៏បញ្ជាដកទ័ពថយ ត្រឡប់ទៅនគរសៀមវិញត្រឹមនេះទៅ ។

លុះចំណេរក្រោយមក យាយ ងួន ក៏ទទួលអនិច្ចកម្មទៅ ក្នុងជន្មាយុ ១០០ ឆ្នាំគត់ ដោយរោគជរាពាធ ។ ពួកអ្នកស្រុកជាចំណុះគាត់ ក៏រៀបចំធ្វើបុណ្យតាមប្រពៃណី ហើយបញ្ចុះសពគាត់ ត្រង់កន្លែងផ្ទះដែលគាត់នៅនោះឯង8 ដោយមានប្រក់និងបាំងជញ្ជាំងយ៉ាងសមរម្យ ។

ពួកអ្នកស្រុកដែលពីដើមមកធ្លាប់យកគាត់ជាពំនឹង ក៏នៅរាប់អានគាត់នោះដដែលគឺថា បើអ្នកណាមានកិច្ចការយ៉ាងណា ក៏ចូលទៅសុំទៅបន់ទៅថ្វាយ នៅកន្លែងផ្នូរគាត់នោះឯង ប៉ុន្តែក្នុងជំនាន់នោះ មិនទាន់ហៅថាអ្នកតានៅឡើយទេ នៅត្រឹមតែ "លោកយាយៗ ឬ លោកយាយ ងួន ដដែល" ។

ដោយនឹកគុណូបការៈរបស់គាត់ ពួកអ្នកស្រុកតែងនាំគ្នាទៅបោសសម្អាតទីកន្លែង នឹងពូនផ្នូររបស់គាត់ស្ទើររាល់ថ្ងៃខែ ប៉ុន្តែមិនទាន់មានធ្វើពិធីធំដុំដូចសព្វថ្ងៃនេះទេ ។ ក្រោយមក គាត់ទៅពន្យល់សប្តិដល់អ្នកស្រុកជាពិសេសចាស់ព្រឹទ្ធាចារ្យនៅក្នុងស្រុកភូមិ ដែលជាហេតុឲ្យគេសន្និដ្ឋានថា លោកយាយ ងួន ពិតមែនតែស្លាប់ទៅហើយ ប៉ុន្តែគាត់នៅរាប់អាន ជួយទុក្ខធុរៈពួកអ្នកស្រុកជាកូនចៅ ដូចកាលគាត់រស់នៅនោះដដែល ។

លុះកន្លងក្រោយមក ទើបមានចូលជាន់រូប ។ ចាប់តាំងពីពេលជាន់រូបមក ពួកស្រុកនិងយាយ ងួន បាននិយាយឆ្លើយឆ្លងគ្នា ទៅវិញទៅមក តាមរយៈរូបដែលចូលមកនោះ ហើយជំនាន់ក្រោយៗ បន្តិចមក មានអ្នកខ្លះហៅថា "អ្នកតាលោកយាយ ឬ លោកយាយ ងួន" ។ ក្រោយមកទៀត កាលនោះ ថាមានទ័ពយួនបានចូលមកលុកលុយប្រទេសកម្ពុជាយើង បានរាលដាលចូលមកដល់ទីរួមខែត្រកំពង់ស្វាយ លោកតេជោអីដែលឈរត្រួតត្រានៅខែត្រនោះ នឹងចាត់ការតទល់ជាបន្ទាន់ពុំបាន ហើយដោយឮល្បីថាលោកយាយ ងួន មានឫទ្ធានុភាពខ្លាំងពូកែ ធ្លាប់មានស្នាដៃយូរមកហើយនោះ លោកក៏លួចបណ្តោះកងទ័ពខ្លះ ព្រមទាំងគ្រួសារចូលទៅស្នាក់នៅក្នុងភូមិដូងទេរ ក្នុងតំបន់លោកយាយ ងួន នោះដែរ ។ លោកតេជោអីបានចាត់ឲ្យរៀបរណ្តាប់បញ្ជាន់រូបយាយ ងួន មកបន់សុំថា "លែងតែលោកយាយជួយឲ្យកម្រាបទ័ពយួនបានចុះ នឹងរៀបធ្វើបុណ្យយ៉ាងឧឡារិកឧទ្ទិសថ្វាយក្នុង ១ឆ្នាំពីរដង ដូចដែលគេធ្លាប់ធ្វើក្នុងទីឯទៀតៗ" ក្នុងពេលនោះថាយាយ ងួន បានទទួលជួយពេញកម្លាំង ។

លោកតេជោបានផ្ញើលោកជំទាវ និងបុត្រាបុត្រីទុកនៅទីនោះដោយចាត់ការឲ្យមានកងយាមល្បាតយ៉ាងមធ្យ័ត9 រួចលោកហួសទៅទាក់ទងកែនពីខែត្រទន្លេល្ពៅនឹងម្លូព្រៃ មកផ្សំនឹងពួកអ្នកនៅនឹងតំបន់លោកយាយ ងួន នេះ ប្រជុំទ័ពឲ្យយាយ ងួន ប្រោះព្រំឲ្យហើយទើបលើកចេញទៅ បានកម្រាប10 ទ័ពយួនវិនាសអន្តរាយអស់ក្នុងរយៈខែត្រនិងពីក្នុងទឹកដីខ្មែរទៅ ។ លុះបានសុខសាន្តហើយ ទើបត្រឡប់មកយកគ្រួសារទៅទីរួមខែត្រវិញ ។ បន្ទាប់មក លោកបានចាត់ការធ្វើបុណ្យថ្វាយលោកយាយ ងួន គឺ ចាត់ឲ្យធ្វើទីធ្លាមួយសង់សាលាមួយខ្នង ជីកអណ្តូងទឹក១ សម្រាប់ប្រើប្រាស់ក្នុងពេលបុណ្យ ។ តែនៅលើកនេះ ពិធីបុណ្យបានធ្វើចំនួន ៧យប់ ៧ថ្ងៃ ដោយមានព្រះសង្ឃ ១០០អង្គ មកជាអធិបតីនឹងទទួលភត្តផង ព្រមទាំងអញ្ជើញពួក

អ្នកស្រុក និងនាម៉ឺនសព្វមុខមន្ត្រីក្នុងខែត្រគ្រប់ជាន់ថ្នាក់ ព្រមទាំងពួកទ័ពឲ្យមកជួបជុំទទួលការជប់លៀង ក្នុងពិធីបុណ្យដ៏មហោឡារិកនោះដែរ ។ ចាប់តាំងពីពេលនោះមក លោកតេជោព្រមទាំងគ្រួសារ តែងអញ្ជើញទៅធ្វើបុណ្យនាទីយាយ ងួន ប្រចាំរៀងរាល់ឆ្នាំហើយលោកបានដឹកនាំឲ្យសាងវត្តសម្រាប់បួសរៀន និងធ្វើបុណ្យទាន ហើយនិងចាត់ចែងឲ្យមានអ្នករាជការ ត្រួតត្រានៅតំបន់នេះរៀងមក ។ ដល់ឥតអំពីលោកតេជោអីទៅ ពួកអ្នកស្រុកចេះធ្វើតែបុណ្យនេះជាទម្លាប់ជាប់រហូតមកដល់សព្វថ្ងៃ ។